## ៧. ផែនការខាងមុខ : ការពិនិត្យឡើងវិញ និងការអភិវឌ្ឍ ESP/ESSP ២០០៤-០៨

### ៧.១ គោលការណ៍ណែនាំសំរាប់កសាង ESP និង ESSP ឆ្នាំ២០០៤-០៨

វត្ថុបំណងសំខាន់នៃដំណើរការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤ គឺត្រូវប្រើប្រាស់របាយការណ៍បំពេញការងារវិស័យអប់រំពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៤ ធ្វើជាមូលដ្ឋានសំរាប់ការពិនិត្យឡើងវិញ សេចក្តីព្រាងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ ។

កំណែលំអយុទ្ធសាស្ត្រសំខាន់ៗ ដែលបានបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ មានសង្ខេបដូចខាងក្រោម ក) យុទ្ធសាស្ត្រកាត់បន្ថយឧបសគ្គចំណាយចំពោះការចូលរៀននៅកំរិតអប់រំមូលដ្ឋាន ខ) គោលវិធីថ្មីដើម្បីកែលំអការឡើងថ្នាក់ និងការបោះបង់ការសិក្សា រួមទាំងកម្មវិធីចូលរៀនឡើងវិញ គ) យុទ្ធសាស្ត្រកែលំអការចូលរៀន និងគុណភាពនៅឧត្តមសិក្សាអោយបានប្រសើរឡើង ឃ) វិធានការបន្ថែមទៀត ដើម្បីធានាដល់ការផ្តល់ហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សំរាប់ជួយជនក្រីក្រ ង) វិធានការថ្មី ដើម្បីធានាអោយការបំពេញការងាររបស់បុគ្គលិកអប់រំ និងការពង្រាយគ្រូប្រកបដោយប្រសិទ្ធភាព ច) ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានថ្មី ដើម្បីពង្រឹងវិមជ្ឈការ និងកំណែទំរង់ស្ថាប័នដទៃទៀត ។

ក្រសួងអប់រំ យុវជន និងកីឡាក៏កំពុងផ្សព្វផ្សាយឯកសារក្របខ័ណ្ឌកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤-០៨ ដែលបានតាក់តែងឡើងសំរាប់ជាគោលការណ៍រួម និងលក្ខខណ្ឌមួយចំនួនដែលត្រូវលំអិតជាកម្មវិធីអាទិភាពនឹងត្រូវរៀបចំឡើងនៅខែខាងមុខ។ ការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤ នឹងផ្តល់នូវឱកាសជាដំបូង ដល់ការពិភាក្សាគ្នាទៅវិញទៅមកដូចជា ក) អាទិភាពរបស់កម្មវិធី ដោយបញ្ចូលកម្មវិធីថ្មីៗ ខ) ការបែងចែកថវិកាសំរាប់កម្មវិធី គ) ការងារគ្រប់គ្រង និងអនុវត្តរង្វាយតំលៃសមត្ថភាពបំពេញការងារ និង ការរៀបចំសំរាប់ពេលអនាគត ។

### ៧.២ ក្របខ័ណ្ឌពិនិត្យឡើងវិញ ESP និង ESSP ឆ្នាំ២០០៤-០៨

#### ៧.២.១. ដំណើរការពិនិត្យមើលផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨

ក្រសួងអប់រំ យុវជន និងកីឡាចាត់ទុក ការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤ ជាឱកាសមួយដើម្បីវាយតំលៃរួមគ្នាលើបញ្ហាសំខាន់ៗ និងជ្រើសរើសលក្ខណៈវិនិច្ឆ័យ សំរាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ ។ សំណួរគន្លឹះ សំរាប់ក្រុមការងារបច្ចេកទេស និងក្រុមពិភាក្សា រួមមាន :

- តើផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ បានផ្តល់យុទ្ធសាស្ត្រល្អៗបែបណាខ្លះ ដល់ការរៀបចំឡើងវិញនូវការអប់រំនិងការបណ្តុះបណ្តាល ដើម្បីធានាចូលរួមក្នុងការសំរេចគោលបំណងរបស់សង្គម ការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ?
- តើផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ ត្រូវការគោលនយោបាយ និងយុទ្ធសាស្ត្របន្ថែមទៀតដែរឬទេ? ឬអាចអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រដែលមានស្រាប់អោយកាន់តែមានប្រសិទ្ធភាព ?

- នៅក្នុងបរិបទរបស់ផែនការអប់រំសំរាប់ទាំងអស់គ្នា តើចំណុចដៅសំរាប់ការពង្រីកសេវាអប់រំក្រោយមធ្យមសិក្សាគ្រប់គ្រាន់ និងជាក់លាក់ដែរឬទេ ? តើរាជរដ្ឋាភិបាលគួរមានតួនាទីអ្វីខ្លះ ?
- តើផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ បានលើកឡើងនូវយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពដើម្បីកែលំអភាពពាក់ព័ន្ធ គុណភាពនិងស្តង់ដាសេវាអប់រំដែរឬទេ? ដោយគិតទាំងតួនាទីនៃអភិបាលកិច្ចល្អ និងលិខិតបទដ្ឋានផ្សេងៗ ។
- តើផែនការហិរញ្ញប្បទាន និងក្របខ័ណ្ឌអភិវឌ្ឍស្ថាប័ន របស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ បានផ្តល់នូវវិធានការដែលមានប្រសិទ្ធភាពឬទេ? ដើម្បីធានាថាការចំណាយអប់រំមានផលប៉ះពាល់ជាអតិបរមា និងធានាអោយមានអ្នកពាក់ព័ន្ធនឹងលទ្ធផល ព្រមទាំងគុណតំលៃនៃការចំណាយ ។
- តើប្រភេទបែបបទផ្តល់ជំនួយពីខាងក្រៅអ្វីខ្លះ ដែលអាចមានប្រសិទ្ធិភាពជាង ដើម្បីជួយសំរេចវត្ថុបំណង និងចំណុចដៅនៃកំណែទំរង់ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៤-០៨ ?

ការពិនិត្យផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ នេះក៏ត្រូវពិនិត្យឡើងវិញលើ ក) ការគ្រប់គ្រង និងការកសាងសមត្ថភាពសំរាប់អនុវត្ត និងកាលវិភាគ ខ) យុទ្ធសាស្ត្រគ្រប់គ្រង និងយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ ។

### ៧.២.២ ដំណើរការពិនិត្យកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤-០៨

ការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤ ក៏ផ្តល់ឱកាសសំរាប់ការពិនិត្យរួមគ្នាលើកម្មវិធី និងគោលការណ៍សំរាប់ចំណាយចរន្ត និងចំណាយជាមូលធន ដែលមានចែងក្នុងឯកសារក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ និងកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤-០៨ បញ្ហាសំខាន់ៗ រួមមាន :

- តើកម្មវិធីសំខាន់ៗនៅក្នុង ESP/ESSP អាចសំរេចវត្ថុបំណងអភិវឌ្ឍន៍រួមរបស់រាជរដ្ឋាភិបាល បានឬទេ? ជាពិសេសយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ គោលដៅនិងចំណុចដៅនៃផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ( ឧទាហរណ៏ អន្តរាគមន៏លក្ខណៈជាប្រព័ន្ធ ឬអន្តរាគមន៏ដោយជ្រើសរើស ) ។
- តើក្របខ័ណ្ឌកម្មវិធីរួមរបស់ ESP/ESSP ទាក់ទងនឹងគោលនយោបាយអប់រំជារួមដែរឬទេ ? ជាពិសេសការបន្ស៊ីគោលដៅ និងចំណុចដៅរបស់ការអប់រំសំរាប់ទាំងអស់គ្នាទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ។
- តើកម្មវិធីនីមួយៗមានការវាយតំលៃជាលក្ខណៈបច្ចេកទេសដែរឬទេ ? ហើយសមាសភាគណាមួយ ត្រូវការអោយមានការកែលំអ និងវាយតំលៃបន្ថែម ពិសេសយកចិត្តទុកដាក់លើអ្នកក្រីក្រ និងក្រុមជួបការលំបាក ?
- តើអន្តរាគមន៏ណាមួយដែលផ្តល់លទ្ធផលអោយឃើញពី ការចំណាយបន្ថែម និងការសន្សំសំចៃ ហើយការគាំទ្រជំនួយពីខាងក្រៅយ៉ាងដូចម្តេច ដើម្បីអោយមានប្រសិទ្ធភាព ?
- តើមានសមត្ថភាពក្នុងការគ្រប់គ្រង និងបច្ចេកទេសគ្រប់គ្រាន់ដែរឬទេ ? តើមានលទ្ធភាពដំណើរការកំណែទំរង់ស្ថាប័នដែលពាក់ព័ន្ធ និងកម្មវិធីកសាងសមត្ថភាពបានដែរឬទេ ?
- តើមានកាលានុវត្តភាព និងហានិភ័យអ្វីខ្លះ ? តើយើងត្រូវគ្រប់គ្រង និងកាត់បន្ថយយ៉ាងដូចម្តេច ?

- តើរដ្ឋាភិបាល និងភ្នាក់ងារសំខាន់ៗផ្សេងទៀតដែលពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធី គួរមានតួនាទីអ្វីខ្លះ? តើធ្វើដូចម្តេចអោយការចូលរួមរបស់អ្នកពាក់ព័ន្ធ បានល្អប្រសើរឡើង ?

ក្រុមការងារពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំ នឹងអនុវត្តតាមគោលវិធីវិភាគតាមបែប SWOT ក្នុងការដោះស្រាយបញ្ហាទាំងនេះ ។

## ៧.៣ ការពង្រឹងភាពជាដៃគូក្នុងវិស័យអប់រំ

ការពិនិត្យឡើងវិញ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤-០៨ នឹងផ្តល់ឱកាសមួយដើម្បីពិនិត្យមើលការរៀបចំភាពជាដៃគូអប់រំ ដែលរួមមាន :

- តើដំណើរការកសាងភាពជាដៃគូត្រូវបង្កើនការអភិវឌ្ឍយ៉ាងដូចម្តេច? ដើម្បីជួយដល់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤-០៨។
- ការពិនិត្យឡើងវិញម៉ាទ្រិកសកម្មភាពគោលនយោបាយរួមបច្ចុប្បន្ន និងកំណត់ចំណុចដៅ ដើម្បីជួយសំរួលដល់ការកែលំអគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ ។
- កាលវិភាគសំរាប់ការពិនិត្យឡើងវិញរួមគ្នាលើកង្វះខាតបរិមាណ និង សក្តានុពលនៃជំនួយពីខាងក្រៅ និងបែបបទផ្តល់ជំនួយ ដែលឆ្លើយតបទៅនឹងកំណែលំអផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំដែរឬទេ ?

របាយការណ៍នៃការពិនិត្យឡើងវិញ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤ នឹងដោះស្រាយបានរាល់បញ្ហាទាំងនេះ ដែលជាផ្នែកមួយនៃការណែនាំដល់ក្រុមសំរបសំរួលការពិនិត្យឡើងវិញ និង វាយតំលៃរួមគ្នាលើកម្មវិធីគាំទ្រវិស័យអប់រំ ។